# សេចក្តីប្រកាសព័ត៌មាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី សូមប្រកាសជូនសាធារណៈជនអោយបានជ្រាបថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ស្ម័គ្រចិត្តបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ដែលអនុវត្តទៅតាមស្តង់ដាគណនេយ្យកម្ពុជា (CAS) ដើម្បីជាព័ត៌មានដល់អ្នកវិនិយោគិន និងភាគីដែលពាក់ព័ន្ធទាំងអស់ ក្នុងការទទួលបានទិន្នន័យហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ប្រកបដោយតម្លាភាព។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី នឹងធ្វើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ដែលអនុវត្តទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ជាសាធារណៈយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។ ការខកខានក្នុងការផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ ដែលអនុវត្តទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដោយសារតែ (១) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី កំពុងស្ថិតក្នុងដំណើរការនៃការកែប្រែស្តង់ដារបាយការណ៍ជាមួយនឹងក្រុមហ៊ុនសវនកម្ម Deloitte ដែលគ្រោងនឹងបញ្ចប់នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ (២) ក្រុមហ៊ុនសវនកម្មទាមទារនូវការគាំទ្រផ្នែកធនធានមនុស្សពីក្រៅប្រទេស ដើម្បីអនុវត្តស្តង់ការគណនេយ្យ IFRS 9។

ថ្ងៃពុធ ១៤កើត ខែអាស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

## Press Release

LOLC (Cambodia) Plc. ("LOLC") has its honor to announce to the public that LOLC volunteered to disclose its financial report as of quarter 2 of 2019, which complies with Cambodian Accounting Standard ("CAS"), for investors and other stakeholders to obtain LOLC's financial data with transparency. LOLC will disclose financial report as of quarter 2 of 2019 in compliance with Cambodian International Financial Reporting Standard ("CIFRS") by November 14$^{th}$, 2019. Failure to disclose financial report as of quarter 2 of 2019 in compliance with CIFRS are due to (1) LOLC is working with audit firm (Deloitte) to standardize its financial report following CIFRS, and (2) audit firm requires human resources from overseas in order to implement IFRS 9.

Phnom Penh, August 14$^{th}$, 2019